# អេស៊ីលីដា ត្រេននីង សេនធ័រ

# ACLEDA Training Center Ltd.

**ការិយាល័យកណ្ដាល**

លេខ : អត្រស ១៩៤២ /១៤

**អគ្គនាយក អេស៊ីលីដា ត្រេននីង សេនធ័រ**

**គោរពជូន**

**នាយក-នាយិកា ធនាគារ អេស៊ីលីដា ភីអិលស៊ី គ្រប់សាខារាជធានី-ខេត្ត-ក្រុង**

**និងសាខាស្រុកកម្រិត " ក "**

**កម្មវត្ថុ : វគ្គបំពាក់បំប៉នអនុប្រធានបេឡាធិការ**

**យោង** : - សេចក្ដីសម្រេចលេខ : អត្រស ០៩៧/១៤ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤ ស្ដីពីការដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវគោលការណ៍ប្រតិបត្តិហ្វឹកហ្វឺន និងអភិវឌ្ឍន៍ធនធានមនុស្ស ។

- អនុស្សរណៈនៃការយោគយល់គ្នាស្ដីពី កិច្ចសហប្រតិបត្តិការ និងគាំទ្រ លើសេវាហ្វឹកហ្វឺនផ្ទៃក្នុងកម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី រវាង ធនាគារ អេស៊ីលីដា ភីអិលស៊ី និង អេស៊ីលីដា ត្រេននីង សេនធ័រ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៣ និងការធ្វើវិសោធនកម្ម ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៣ ។
- ផែនការបណ្ដុះបណ្ដាលប្រចាំឆ្នាំ ២០១៤ ។
- លិខិតលេខ : កធម ២៣៩១/១៤ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៤ ស្ដីពីតម្រូវការរៀបចំបើកវគ្គបំពាក់បំប៉នអនុប្រធានបេឡាធិការសាខា " ក " ។

តបតាមកម្មវត្ថុ និងយោងខាងលើ អេស៊ីលីដា ត្រេននីង សេនធ័រ នឹងមានរៀបចំបើកវគ្គបំពាក់បំប៉ន **អនុប្រធានបេឡាធិការគ្រប់សាខារាជធានីខេត្ត-ក្រុង និងសាខាស្រុកកម្រិត " ក "** ដែលនឹងប្រព្រឹត្តទៅជា **ពីរវគ្គ** ៖

**<u>វគ្គទី១</u> : ថ្ងៃទី ០៨ ដល់ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៤**

**<u>វគ្គទី២</u> : ថ្ងៃទី ១៥ ដល់ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៤**

នៅ**អេស៊ីលីដា ត្រេននីង សេនធ័រ ជាន់ទី៣ បន្ទប់ប្រាសាទអង្គរវត្ត** ដូចមានកាលវិភាគ និងបញ្ជីរាយនាមសាខា ជូនភ្ជាប់មកជាមួយ ។

អាស្រ័យហេតុនេះ សូមលោកនាយក-នាយិកា មេត្តាចាត់បញ្ជូនកម្មករនិយោជិត ដែលមានមុខតំណែងដូចខាងលើឲ្យចូលរួមក្នុងវគ្គបំពាក់បំប៉នតាមកាលបរិច្ឆេទ និងទីកន្លែងដូចបានជម្រាបជូន ។

សូមលោកនាយក-នាយិកា ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤

**ជ, អគ្គនាយក**

**នាយិកាការិយាល័យសិក្សា និងកិច្ចការនិស្សិត**

**<u>ជូនភ្ជាប់មកជាមួយ</u>**
- កាលវិភាគវគ្គបំពាក់បំប៉ន
- បញ្ជីរាយនាមសាខាដែលត្រូវចូលរួម

**<u>ចម្លងជូន</u>**
- នាយកប្រតិបត្តិប្រតិបត្តិការ, អភិវឌ្ឍន៍ផលិតផល, ហិរញ្ញប្បទានពាណិជ្ជកម្ម
- អគ្គនាយក អេស៊ីលីដា ស៊ុយប្បូរីធី ភីអិលស៊ី
- នាយក-នាយិកាការិយាល័យរតនពាណិជ្ជកម្ម, គ្រប់គ្រងទ្រព្យសកម្ម និងអកម្ម, រតនាភិបាល, គ្រប់គ្រងហានិភ័យ និងប្រតិបត្តិ
- នាយកការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍
- នាយកការិយាល័យទំនាក់ទំនងសាធារណៈ
- នាយកគ្រប់ការិយាល័យសវនកម្ម
- ជំនួយការនាយិកាការិយាល័យធនធានមនុស្ស

" **ដើម្បីជូនជ្រាបជាព័ត៌មាន** "

- ឯកសារ-កាលប្បវត្តិ

This is an electronic letter sent by Sovanne Tourt